មើលវីដេអូ ភាគទី ៣៣

# វិនិច្ឆ័យអភិជ្ឈា (ការសំលឹងរំពៃចង់បាននូវភណ្ឌៈរបស់អ្នកដទៃ) ដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល២ គឺលោភមូល និងមោហមូល |
| ២ - ដោយកម្ម | ជាមនោកម្ម |
| ៣ - ដោយទ្វារ | សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ |

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## អភិជ្ឈា កើតតាម ទ្វារ៣

**តាមមនោទ្វារ** ខណៈពេលដែលគិត ប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ។



**តាមវចីទ្វារ** ខណៈពេលដែលគិត ប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ ក៏និយាយចេញមក។



**តាមកាយទ្វារ** ខណៈពេលដែលគិត ប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ ក៏ធ្វើតាមគំនិតនោះ។



| | |
|---|---|
| ៤ - ដោយទោស | មានទំនងដូចអទិន្នាទាន |
| ៥ - ដោយអង្គ | អភិជ្ឈា មានអង្គ២ គឺ ៖ |
| - បរភណ្ឌំ | ទ្រព្យរបស់អ្នកដទៃ |
| - អត្តនោ បរិណាមនំ | បង្អោនមកជារបស់ខ្លួន (ដោយបំណងអាក្រក់)។ |

## វិនិច្ឆ័យព្យាបាទ (បំណងចង់ឲ្យគេវិនាស) ដោយអាការ ៥ ៖

១- ដោយមូល មានមូល ២ គឺ ទោសមូល និងមោហមូល

២- ដោយកម្ម ជាមនោកម្ម

៣- ដោយទ្វារ សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ

# ព្យាបាទកើតតាមទ្វារ៣

តាមមនោទ្វារ ខណៈដែលមានសេចក្តី
ខឹងក្រោធខ្លាំង ក៏គិតចង់ឲ្យគេវិនាស
ដោយ ទុច្ចរិតកម្មផ្សេងៗ ។





តាមវចីទ្វារ ខណៈដែលមានសេចក្តី
ខឹងក្រោធខ្លាំង រហូតគិតចង់ឲ្យគេវិនាស
រួចក៏និយាយចេញមកតាមគំនិតនោះ។

តាមកាយទ្វារ ខណៈដែលមានសេចក្តី
ខឹងក្រោធខ្លាំង រហូតគិតចង់ឲ្យគេវិនាស
រួចក៏ធ្វើសកម្មភាពតាមគំនិតនោះ។



| | |
|---|---|
| ៤- ដោយទោស | មានទំនងដូចផរុសវាទ |
| ៥- ដោយអង្គ | ព្យាបាទ មានអង្គ ២ គឺ ៖ |
| - បរសត្តោ | សត្វដទៃ |
| - តស្ស ច វិនាសចិន្តោ | គិតឲ្យសត្វដទៃនោះវិនាស ។ |

# វិនិច្ឆ័យមិច្ឆាទិដ្ឋិ (ការឃើញខុសចាកសេចក្ដីពិត) ដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល ២ គឺលោភមូល និងមោហមូល |
| ២ - ដោយកម្ម | ជាមនោកម្ម |
| ៣ - ដោយទ្វារ | សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ |

## ៤ - ដោយទោស

- សេពច្រើន មានទោសច្រើន
- សេពតិច មានទោសតិច
- យល់ខុសស៊ប់ មានទោសច្រើន
- យល់ខុសមិនស៊ប់ មានទោសតិច

៥ - ដោយអង្គ មិច្ឆាទិដ្ឋិ មានអង្គ២ គឺ ៖

- វត្ថុនោ ច គហិតាការវិបរិតតា ចិត្តប្រែប្រួលដោយសភាព ខុសចាកអាការគួរកាន់យក មានព្រះរតនត្រៃជាដើម។

- យថា ច តំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ ការប្រកាន់នូវរឿង មិនពិតនោះក៏ប្រាកដ។

## សង្គហគាថា

*អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា*

*មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ។*

អកុសលចិត្ត ១២ គឺ លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មោហមូលចិត្ត ២។